ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

## រយៈពេល ៣ ឆ្នាំ

## (២០០៨-២០១០)

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | : អភិរក្សធនធានជលផលតាមល់លើ |
| ភូមិ | : តាមល់លើ |
| ឃុំ | : កោះថ្កូវ |
| ស្រុក | : ជលគិរី |
| ខេត្ត | : កំពង់ឆ្នាំង |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

## រយៈពេល ៣ ឆ្នាំ

## (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : អភិរក្សធនធានជលផលតាមល់លើ

ភូមិ : តាមល់លើ

ឃុំ : កោះថ្កូវ

ស្រុក : ជលគីរី

ខេត្ត : កំពង់ឆ្នាំង

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ **អភិរក្សធនធានជលផលតាមល់លើ** ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី **១៨** ខែ **ឧសភា** ឆ្នាំ **២០០៧** និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី **១១** ខែ **មករា** ឆ្នាំ **២០០៨**។

សហគមន៍នេសាទ **តាមល់លើ** មានទីតាំងស្ថិតនៅក្នុងភូមិ **តាមល់លើ** ឃុំ **កោះថ្កូវ** ស្រុក **ជលគីរី** ខេត្ត **កំពង់ឆ្នាំង** ដែលមានសមាជិកសរុបចំនួន **៤២២** នាក់ ស្រីចំនួន **១៩៩** នាក់ និង មានគណៈកម្មការ ចំនួន **១១** នាក់ ស្រីចំនួន **១** នាក់។ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន **១៦៥** គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន ៖

- លក្ខន្តិកៈសហគមន៍នេសាទ និងបទបញ្ជាផ្ទៃក្នុង
- ផែនទីសហគមន៍
- កិច្ចព្រមព្រៀង
- សហការជាមួយមេភូមិ និងក្រុមប្រឹក្សាឃុំ
- សហការជាមួយជំនាញជលផល
- ធ្វើល្បាតក្នុងតំបន់សហគមន៍នេសាទ

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក-ប្រជាពលរដ្ឋ:

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន **១៦០៦** នាក់ ប្រុស **៧៨៦** នាក់ ស្រី **៨២០** នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន **១៦០៦** នាក់ ខ្មែរឥស្លាមចំនួន **គ្មាន** អាណិកជនវៀតណាមចំនួន **គ្មាន**។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ៦០ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ២២ នាក់ ស្រី ៥ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៣០ នាក់ ស្រី ២០ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ៤ នាក់ ស្រី ១ នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន ២០ នាក់ ស្រី ១៥ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ **១០០ %**។ ក្រៅពីនេះមានអ្នកកាន់សាសនាអ៊ីស្លាមប្រមាណ **គ្មាន %** សាសនាកាតូលិកប្រមាណ **គ្មាន %**។

- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន **៣០** នាក់ ស្រី **១៨** នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន **២១០** នាក់ ស្រី **១០០** នាក់ កំរិតមធ្យមសិក្សាចំនួន **៥០** នាក់ ស្រី **១៦** នាក់ និងកំរិតថ្នាក់ឧត្តមសិក្សា **គ្មាន**។

**ខ-មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន :

- ធ្វើនេសាទចំនួន ៣១០ នាក់
- ធ្វើស្រែប្រាំងចំនួន ២០០ គ្រួសារ ទំហំ ៩៩៩ ហិកតា
- ធ្វើវារីវប្បកម្មចំនួន ៩ គ្រួសារ ចំនួន ៩ ស្រះ
- ដាំបន្លែចំនួន ១៦៥ គ្រួសារ ទំហំ ២៣ ហិកតា
- ដាំឈូកចំនួន ៣០ គ្រួសារ ទំហំ ១២,៥ ហិកតា
- កែច្នៃផលនេសាទ ១៦៥ គ្រួសារ
- ជាងផ្ទះចំនួន ៦ គ្រួសារ
- ត្បាញកន្ទេលចំនួន ២០ គ្រួសារ
- ជាងទូក ១២ គ្រួសារ
- រត់ទូកដរចំនួន ៤ គ្រួសារ
- លក់ដូរ ២ គ្រួសារ
- ម៉ាស៊ីនកិនស្រូវ ១០ គ្រួសារ
- ជាងឈើចំនួន ១ នាក់
- ស៊ីឈ្នួលគេចំនួន ២០ គ្រួសារ
- កាត់ដេរចំនួន ១៥ នាក់
- បញ្ចូលអាគុយ ១ គ្រួសារ

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍ **តាមល់លើ** ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទលេខ **១៦**។ កន្លែងនេសាទសហគមន៍ **តាមល់លើ** មានទំហំ **២៣៦៥** ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ :

- ខាងជើងទល់នឹង **សហគមន៍នេសាទកោះថ្កូវ**

- ខាងត្បូងទល់នឹង **សហគមន៍នេសាទតាមល់ក្រោម**
- ខាងកើតទល់នឹង **ស្រុកបាធាយ ខេត្តកំពង់ចាម**
- ខាងលិចទល់នឹង **មាត់ទន្លេកប៉ាល់**

**៤. ដែននេសាទ**

កន្លែងនេសាទសហគមន៍ **តាមល់លើ** មានបឹងចំនួន **១០** ព្រែកចំនួន **៣** មេទឹកចំនួន **៨** និងព្រៃលិចទឹកចំនួន **២** កន្លែង។

| | | |
|---|---|---|
| - បឹងឈ្មោះ **កាបោរ** | ទំហំ ៥០ម x ១.០០០ម | នេសាទ ពេញមួយឆ្នាំ |
| - បឹងឈ្មោះ **តាមល់** | ទំហំ ៧០ម x ២.០០០ម | នេសាទ ពេញមួយឆ្នាំ |
| - បឹងឈ្មោះ **កន្លែងត្នោត** | ទំហំ ២៥ ហិកតា | នេសាទ ពេញមួយឆ្នាំ និងដាំឈូក |
| - បឹងឈ្មោះ **វិចេក** | ទំហំ ៣០ម x ២០០ម | នេសាទ ពេញមួយឆ្នាំ |
| - បឹងឈ្មោះ **ឡុច** | ទំហំ ៥០ម x ១.៥០០ម | នេសាទ ពេញមួយឆ្នាំ |
| - បឹងឈ្មោះ **ប្រា** | ទំហំ ៥០ម x ១.០០០ម | នេសាទ ពេញមួយឆ្នាំ |
| - បឹងឈ្មោះ **ត្រីពោធិ៍** | ទំហំ ៦០ម x ៨០០ម | នេសាទ ពេញមួយឆ្នាំ |
| - បឹងឈ្មោះ **តាឆាក** | ទំហំ ៤០ម x ៨០០ម | នេសាទ ពេញមួយឆ្នាំ និងដាំឈូក |
| - បឹងឈ្មោះ **កន្ទប** | ទំហំ ៧០ម x ១០០ម | នេសាទ ពេញមួយឆ្នាំ |
| - បឹងឈ្មោះ **កំភ្លាញ** | ទំហំ ៨០ម x ២០០ម | នេសាទ ពេញមួយឆ្នាំ |
| - ព្រែកឈ្មោះ **ល្វា** | ទំហំ ២០ម x ២០០ម | នេសាទពីខែ ធ្នូ ដល់ខែ មករា |
| - មេទឹក **វិចេក** | ទំហំ ១០ ហិកតា | នេសាទពីខែ កុម្ភៈ ដល់ខែ មេសា |
| - មេទឹក **ព្រៃខ្មោច** | ទំហំ ១០ ហិកតា | ពុំធ្វើនេសាទ ( យកទឹកដាក់ស្រែប្រាំង) |
| - មេទឹក **តាយឿន** | ទំហំ ០៩ ហិកតា | នេសាទពីខែ មេសា |
| - មេទឹក **កន្លែងស្បូវ** | ទំហំ ០៥ ហិកតា | ពុំធ្វើនេសាទ ( យកទឹកដាក់ស្រែប្រាំង) |
| - មេទឹក **ទំនប់ថ្មី** | ទំហំ ១៧០ហិកតា | នេសាទពីខែ មករា ដល់ខែ មេសា |
| - មេទឹក **ខ្នាក្រាប** | ទំហំ ២២២ហិកតា | នេសាទពីខែ មករា ដល់ខែ មេសា |
| - មេទឹក **ដីក្រហម** | ទំហំ ២៨០ហិកតា | នេសាទពីខែ មករា ដល់ខែ មេសា |
| - មេទឹក **ចំពាមបី** | ទំហំ ៤៥ ហិកតា | នេសាទពីខែ មករា ដល់ខែ មេសា |
| - ព្រៃលិចទឹក **មេទឹកវិចេ** | ទំហំ ៧ ហិកតា | |
| - ព្រៃលិចទឹក **ព្រៃខ្មោច** | ទំហំ ២ ហិកតា | |

- ដីទំនាបលិចទឹកមានទំហំសរុប **២៣៦៥** ហិកតា។

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

- បឹង**កន្លែងត្នោត** ទំហំ **២,៥** ហិកតា (បណ្តោយ ២៥០ម និងទទឹង ១០០ម)
- បឹង **ច្បុច** ទំហំ **៧,៥** ហិកតា (បណ្តោយ ១.៥០០ម និងទទឹង ៥០ម)
- ព្រៃលិចទឹកបឹងរំចេ ទំហំ ៧ ហិកតា
- ព្រៃលិចទឹកព្រៃខ្មោច ទំហំ ២ ហិកតា
- ព្រៃទំនាបបឹងកន្លែងត្នោត ទំហំ ១ ហិកតា

**ឃ. ធនធានជលផល**

- ប្រភេទត្រី ៖
  - ➢ ប្រភេទត្រីដែលមានការកើនឡើង ៖ ត្រីរៀល ច្រកែង ឆ្ពិន សង្កត់ប្រាក់ ខ្នងវែង ចង្វា កញ្ចាញ់ច្រាស់ និងត្រីប្រម៉ា។
  - ➢ ប្រភេទត្រីដែលមិនថយ និងមិនកើនឡើង ៖ ត្រីលិញ កាហែ រ៉ស់ ឆ្តោ ឆ្លាំង ក្រុស ឆ្លូញ ច្រឡឹក និងត្រនេល។
  - ➢ ប្រភេទត្រីដែលមានការថយចុះ ៖ ត្រីក្រម៉ម ក្អែក ត្រីគ្រុំ ក្រពាត់ សណ្តាយ ពោធិ៍ ប្រា កញ្ចុន ដំរី កន្ធរ អណ្តែង ក្រាយ ក្រាញ់ កន្ទ្រប់ ស្រកាវក្តាម ផ្ទក់គរ ខ្ទឹង កញ្ជ្រូក កន្ទ្រង់ប្រេង ឆ្វា ឆ្តោកទិទុយ ត្រសក់ ឆ្តោក ព្រួល ព្រលួង ខ្ទាន់ ស្លាត ក្រាយ។
- ប្រភេទវារីសត្វ ៖ ពស់ អណ្តើក ក្តាម ខ្យង ខ្ចៅ កំពិស គ្រុំ លាស និងអន្ទង់។
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ៖ ត្រស់ រាំង អញ្ចាញ បបួយ ទានព្រៃ ថ្មើមអណ្តើក អាញ្ញេរ ខុម ត្រសក់ ផ្លែប៉ូវ ក្អែកព្រាប អាព្រៀម វល្លិ៍តាអើក វល្លិ៍ត្រដិត វល្លិ៍ប្រេង វល្លិ៍ដូងព្រះ វល្លិ៍ត្រី សួត ញ ប៉ជិញញី ប៉ជិញឈ្មោល ទន្លា ឫស្សី ម៉ូយ អំពិលបារាំង អាវក្រពើ រំចង់ ព្រលិត ត្រកួន ជន្ទល់ភ្នំ ក្រចាប់ កក់ សារាយ ស្មោ ត្រែង ស្បូវ ស្មៅស្មោង ស្មៅកាស ស្មៅត្រណោតអន្ទង់ ស្រម៉ៃ ជីប៉ូង ប្រកអណ្តើក រពាក់ទឹក ផ្គុង វល្លិ៍ជុយ កំពីងពួយ កន្ទាំងហែ កំប្លោក ចក ដើមផ្ទោល ត្នួរ ស្មៅចិញ្ចៀន ស្មៅពក បន្លាយួន រំទឹក ស្មៅជើងក្រាស វល្លិ៍មាស វល្លិ៍សាវម៉ាវព្រៃ វល្លិ៍ត្រដិត បន្លាស្អិត បន្លាឃ្លេ ល្បៀង ក្រ កប្បាស់ព្រៃ វល្លិ៍ស្លាបកុក អណ្តាតត្រកួត ស្លាបទា គរ សណ្តាន់ ច្រកែង ចាក ពោធិ៍ ថ្នាន់ អំពិល។

**៤. ការធ្វើនេសាទ**

**ក. អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន **៣១០** នាក់ ស្រី **១២០** នាក់

- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន **២២០** នាក់ ស្រី **១០៩** នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន **១៣០** នាក់ ស្រី **៣០** នាក់។

## ៩. ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទៈ

| **ប្រភេទឧបករណ៍** | **ឯកតា** | **ចំនួន** | **ទំហំ/ប្រវែង** | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ១ដៃ=៨០ | (២ដ×១៥០ន)=៣០០ដ | -ប្រវែង=៦០០០ម<br>-ក្រឡា=២.៥-៦សម-ជំរៅ=១.៥ម | កញ្ញា-កុម្ភៈ |
| សន្ទូចរនង | ផ្លែ | ២០០ផ្លែ x ២០ន | ៤០០០ផ្លែ.លេខ=១១-១៥ | កញ្ញា - វិច្ឆិកា |
| សន្ទូចបង្កៃ | ផ្លែ | ១០០ផ្លែ x ១០ន | ១០០០ ផ្លែ | មករា - កុម្ភៈ |
| អង្រុត | គ្រឿង | ១គ្រx ១០ន | ១០ គ្រឿង | មិនា - មេសា |
| សំណាញ់ | វង់ | (១វង់×១០ន)= ១០វង់ | ប្រវែង៧ម.ក្រឡា ២សម | កញ្ញា - តុលា |
| លប | គ្រឿង | (២គ្រ×២០ន)=៤០គ្រ | -មុខកាត់= ៨០សម<br>-ប=១.៥ម-ក្រឡាគ្រៀម=១.៥សម | កញ្ញា - តុលា |

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| ទូកចែវ | ៣២០ គ្រឿង | ២០០ គក្រ | |
| កាណូត | ២០០ គ្រឿង | ៥០០-១០០០ គក្រ | ៥-៧.៥ សេះ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

| **ប្រភេទឧបករណ៍** | **ឯកតា** | **ចំនួន** | **ទំហំ/ប្រវែង** | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ១ដៃ=៨០ | (២ដ×៥០ន)=១០០ដ | -ប្រវែង=៨០០០ម<br>ក្រឡា=២.៥-៦សម-ជំរៅ=១.៥ម | កញ្ញា-វិច្ឆិកា |
| សន្ទូចរនង | ផ្លែ | ២០០ផ្លែ x ១០ន | ២០០០ផ្លែ.លេខ=១១-១៥ | កញ្ញា-វិច្ឆិកា |
| សន្ទូចបង្កៃ | ផ្លែ | ១០០ផ្លែ x ១០ន | ១០០០ ផ្លែ | មករា-កុម្ភៈ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ៨០ គ្រឿង | ២០០ គក្រ | |
| កាណូត | ១០ គ្រឿង | ៥០០ គក្រ-២០០០គក្រ | ៥សេះ-១៥ សេះ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ :

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ១ដៃ=៨០ | (២ដ×២០ន)=៤០ដ | -ប្រវែង=៣២០០ម<br>-ក្រឡា=២.៥-៦សម-ជំរៅ=១.៥ម | កញ្ញា-កុម្ភៈ |
| អង្រុត | គ្រឿង | ១គ្រx ២០ន | ២០ គ្រឿង | មិនា-មេសា |
| សំណាញ់ | វង់ | (១វង់X៣០ន)= ៣០វង់ | ប្រវែង៧ម,ក្រឡា ២សម | កញ្ញា-តុលា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ១០០ គ្រឿង | ២០០ គក្រ | |
| កាណូត | ២០ គ្រឿង | ៥០០-២០០០ គក្រ | ៥សេះ -១២ សេះ |

## គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំឆ្នាំ *(គិតជា គក)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ២៥០ គក្រ | ៤៥៣ គក្រ | ៧០៣ គក្រ |
| ក្តាម ខ្យង កង្កែប | ២០០ | ៣០០ គក្រ | ៥០០ គក្រ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនះវិស័យ

សហគមន៍នេសាទ **អភិរក្សធនធានជលផលតាមល់លើ** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធមិ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

## ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុងទំនាបលិចទឹកក្នុងរដូវជំនោរឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌ ។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ ។

## គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលា ធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| បឹងកន្លែងត្នោត<br>បឹង ច្បុច<br>បឹងតាឆាក<br>បឹងត្រីពោធិ៍<br>បឹងតាមល់<br>បឹងរំចេក<br>បឹងកំភ្លាញ<br>បឹងកន្ទប<br>បឹងកន្លែងផ្តៅ | ខែមិនា ដល់ មិថុនា | មង | ប្រវែង= ៣២០០០ម<br>ក្រឡា=២.៥- ៦សម<br>ជំរៅ=១.៥ម<br>២ដៃ=១៦០ម/នាក់ | ២០០នាក់ | |
| | | សន្ទូចរនង | ៣០០ ផ្លែ/នាក់<br>ចំនួន=៩០០០ផ្លែ | ៣០នាក់ | |
| | | សន្ទូចបង្កៃ | ៥០ ផ្លែ/នាក់<br>ចំនួន=១០០០ផ្លែ | ២០នាក់ | |
| | | លប | ២គ្រ /នាក់<br>ចំនួន=៤០គ្រឿង | ២០នាក់ | |
| | | អង្រុត | ១គ្រ/នាក់ | ៣០នាក់ | |

## គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងកន្លែងត្នោត | ២៥ ហត | ១០០ម x ៣០០ម ជ=១ម | -ជីកស្ដារជំរៅ ៣ម ដោយគ្រឿងចក្រ<br>- ដាំព្រៃលិចទឹកព័ទ្ធជុំវិញ | ០១/៤/២០០៩ | ០១/៦/២០១០ | |
| បឹងច្បុច | ៦ ហត | ១០០ម x ៣០០ម ជ=០៧ម | - ថែរក្សាព្រៃមានស្រាប់ បោះបង្គោល និងដាក់ស្លាកសញ្ញា ។<br>- ដាក់ជំរកត្រី<br>- ល្បាត | ០១/៣/២០០៩ | ០១/៦/២០១០ | ការពារព្រៃលិចទឹក |
| តំបន់ជើងទទួលបុរាណខាងលិច | ២៥ ហត | ២៥ ហត | - ថែរក្សាព្រៃមានស្រាប់ បោះបង្គោល និងដាក់ស្លាកសញ្ញា<br>- ដាក់ជមរកត្រី<br>- ល្បាត<br>- បែងចែកតំបន់ដកហូត | ០១/០២/២០០៩ | ០១/៧/២០១០ | |

## គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងកន្លែងត្នោត | ២៥ ហត | អភិរក្សត្រីមេពូជនិងជីវចំរុះ | - ដាំព្រៃលិចទឹក<br>- ដាក់ជមរកត្រី<br>- បោះបង្គោល<br>- ដាក់ស្លាកសញ្ញា | ០១/០២/២០០៩ | ០១/៧/២០១០ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | - ល្បាត | | | |
| បឹងច្បុចផ្នែកខាងត្បូង | ៣ ហាត | អភិរក្សត្រីមេពូជនិងជីវចំរុះ | - ដាំព្រៃលិចទឹក<br>- ដាក់ជម្រកត្រី<br>- បោះបង្គោល<br>- ដាក់ស្លាកសញ្ញា<br>- ល្បាត | ០១/០២/២០០៩ | ០១/៧/២០១០ | |
| តំបន់ជើងទទួលបុរាណខាងលិច | ២៥ ហាត | ប្រភេទព្រៃលិចទឹក | - ដាំព្រៃបន្ថែម<br>- ធ្វើរបង<br>- ដាក់ស្លាកសញ្ញា<br>- បោះបង្គោល<br>- ល្បាត | ០១/០២/២០១០ | ០១/៧/២០១០ | |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំនិងការពារ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១-តំបន់ជើងទទួលបុរាណខាងលិច | ២៥ ហាត | ព្រៃលិចទឹក | - បោះស្លាក<br>- បោះបង្គោល<br>- បែងចែកតំបន់ដកហូត | ០១/០១/២០០៩ | ៣០/៧/២០១០ | |
| ១-តំបន់ជើងទទួលបុរាណខាងលិចទី ១ | ៩ ហាត | ព្រៃលិចទឹកដើមធំ | ដករំលោះមែក | ០១/០១/២០០៩ | ៣០/១២/២០១០ | |
| ២-តំបន់ជើងទទួលបុរាណខាងលិចទី ២ | ៩ ហាត | ព្រៃលិចទឹកដើមធំ | ដករំលោះមែក | ០១/០១/២០០៩ | ៣០/១២/២០១០ | |
| ៣-តំបន់ជើងទទួលបុរាណខាងលិចទី ៣ | ៧ ហាត | ព្រៃលិចទឹកដើមធំ | ដករំលោះមែក | ០១/០១/២០១០ | ៣០/១២/២០១០ | |

## គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ស្រះ (៥ម x ៨ម x ២.៥ម) | ៣០ | - ប្រា<br>- អណ្តែង<br>- ឆ្ពិន<br>- ច្រឡឹង<br>- កាហែ ក្រឡង់ | ១០០.០០០កូន | ០១/១១/២០០៩ | ៣០/៧/២០១០ |
| ស្រះ (៦ម x ១២ម x ២.៥ម) | ៤០ | - ប្រា<br>- អណ្តែង<br>- ឆ្ពិន<br>- ច្រឡឹង<br>- កាហែ ក្រឡង់ | ១៣០.០០០កូន | ០១/១១/២០០៩ | ៣០/៧/២០១០ |
| ស្រះ (៤ម x ៨ម x ២ម) | ៥១ | - ប្រា<br>- អណ្តែង<br>- ឆ្ពិន<br>- ច្រឡឹង<br>- កាហែ ក្រឡង់ | ១៦០.០០០កូន | ០១/១១/២០១០ | ៣០/៧/២០១១ |

### គ-៦ ផែនការចរិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ប្រមូលពីសមាជិក | ០១/០១/២០០៨ | ៣០/៨/២០០៩ | ២៥០.០០០៛ | |
| ភាគទានប្រចាំឆ្នាំ | ប្រមូលពីសមាជិក | ០១/៧/២០០៩ | ៣០/១២/២០០៩ | ៥០០.០០០៛ | |
| ភាគទានប្រចាំឆ្នាំ | ប្រមូលពីសមាជិក | ០១/៧/២០១០ | ៣០/១២/២០១០ | ៥០០.០០០៛ | |

### គ-៧ ផែនការផ្សេងៗទៀត

ទន្ទឹមនឹងផែនការខាងលើ សហគមន៍នេសាទក៏មានផែនការចំពោះមុខមួយចំនួនទៀតដើម្បីដោះស្រាយនូវបញ្ហាដែលកើតមានចំពោះមុខ ។ បញ្ហាចំពោះមុខមាន ខ្វះសម្ភារៈប្រើប្រាស់ក្នុងសហគមន៍ (ទូក កាណូត សម្ភារៈសំរាប់បំរើការងាររដ្ឋបាល ល្បាត និងការទុកដាក់ឯកសារជាដើម), បទល្មើសនេសាទសំរះ និងឆក់, បញ្ហាបឹងរីងរាក់, គ្មានព្រៃលិចទឹក, គ្មានទឹកស្អាតសំរាប់ប្រើប្រាស់, គ្មានស្នាក់ការសហគមន៍, គ្មានបង្គន់អនាម័យប្រើប្រាស់, គ្មានបច្ចេកទេសក្នុងការដាំដុះ និងចិញ្ចឹមសត្វ, គ្មានមុខរបរបន្ថែម, ខ្វះទឹកស្រោចស្រពដំណាំ, ខ្វះគ្រូបង្រៀន, ប្រជាជនមានចំណាកស្រុកដើម្បីរកប្រាក់ចំណូល, មានអំពើហឹង្សាក្នុងគ្រួសារ, ខ្វះស្ពាន, គ្មានសាលាមតេយ្យ, គ្មានផ្លូវដឹកជញ្ជូនកសិផល, ខ្វះសាលារៀន, កុមារកំព្រាពុំមានអ្នកជួយទំនុកបំរុង, ខ្វះពូជសត្វចិញ្ចឹម និងគ្មានទួលសុវត្ថិភាព ។

ដោយសារបញ្ហាចំពោះមុខមានច្រើន ហើយពុំដឹងត្រូវដោះស្រាយមួយណាមុខ ទើបគណៈកម្មការសហគមន៍បានធ្វើការកំណត់ និងជ្រើសយកបញ្ហាអាទិភាពចំនួន ៥ មកធ្វើការដោះស្រាយមុនដូចជា : បញ្ហាបឹងរីងរាក់, គ្មានស្នាក់ការ, ខ្វះពូជសត្វចិញ្ចឹម, គ្មានបង្គន់អនាម័យ និងទឹកស្អាត និងគ្មានសម្ភារៈប្រើប្រាស់សំរាប់បំរើការងារសហគមន៍ ។

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ ។
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកចរិកាទ្រទ្រង់ជាដើម

- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និង ជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ ។
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធ សំខាន់ៗដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ តាមល់លើ រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | - តាមដាននិងត្រួតពិនិត្យ<br>- អនុវត្តលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍<br>- ណែនាំនិងផ្សព្វផ្សាយ | - ផលត្រីនឹងកើនឡើង<br>- ការិតចាប់ពីធម្មជាតិត្រូវបានកាត់បន្ថយ<br>- មានការគោរពច្បាប់ | | | ២០០៩ | ២០១០ | |
| ២. ការកែលំអដែននេសាទ | -ជីកស្តារជំរៅពាម ដោយគ្រឿងចក្រ ។<br>- ដាំព្រៃលិចទឹកព័ទ្ធជុំវិញ<br>- ថែរក្សាព្រៃមានស្រាប់<br>- បោះបង្គោលនិងដាក់ស្លាកសញ្ញា ។<br>- ដាក់ជម្រកត្រី<br>- ល្បាត | - សកម្មភាពស្តារត្រូវបានដំណើរការ ។<br>- បឹងព្រែកមានជំរៅធ្វើទឹកមិនរីង និងមានត្រីច្រើនដែលមករស់នៅកន្លែងនេះ ។ | ៣៧០០ ដុល្លា | ផែនការឃុំ | ២០០៩ | ២០១០ | |
| ៣. ការកំណត់ និងរៀបចំតំបន់អភិរក្ស | - ដាំព្រៃលិចទឹក<br>- ដាក់ជំរកត្រី<br>- បោះបង្គោល | - ពូជត្រីកើនឡើង<br>- ប្រជាពលរដ្ឋមានត្រីនេសាទ និងមានចំណូលកើនឡើងសំរាប់គ្រួសារ | ៤០០០ ដុល្លា | ផែនការឃុំ | ២០០៩ | ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | - ដាក់ស្លាកសញ្ញា<br>- ល្បាត | | | | | | |
| ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក | - បោះស្លាក<br>- បោះបង្គោល<br>- បែងចែកតំបន់ដកហូត | - ព្រៃលិចទឹកមានស្ថេរភាព និងមានការដាំបន្ត<br>- មានការដកហូតត្រឹមត្រូវប្រកបដោយចិរភាព<br>- សត្វ និងត្រីមានជំរកកន្លែងពងកូន ចំណីរ | ១៤០០ ដុល្លា | ផែនការឃុំ | ២០០៩ | ២០១០ | |
| ៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | - ចិញ្ចឹមតាមស្រះ<br>- បង្កើតស្រះបន្ថែម<br>- ផ្សព្វផ្សាយ<br>- បង្រៀនបច្ចេកទេស | - មានចំណូលពីការលក់ត្រីដែលចិញ្ចឹម<br>- កាត់បន្ថយការចាប់ពីធម្មជាតិ | ១៧៥០ ដុល្លា | ផែនការឃុំ | ២០០៩ | ២០១០ | |
| ៦- ផែនការរកប្រាក់ចំណូលសហគមន៍ | - ប្រមូលប្រាក់ភាគទាននិងការសុំចូលជាសមាជិកសហ-គមន៍ ។<br>- ចំណូលផ្សេងៗ | - មានការអភិវឌ្ឍន៍<br>-ប្រជាពលរដ្ឋមានជំនឿ<br>- ប្រជាពលរដ្ឋមានរបរបន្ថែម ។ | ៣៥០ ដុល្លា | សមាជិកសហគមន៍ | ២០០៩ | ២០១០ | |
| ៧- ផ្តល់បច្ចេកទេសដាំដុះនិងចិញ្ចឹមសត្វ ។ | - បើកវគ្គបណ្តុះបណ្តាលខ្លីៗ<br>- រៀបចំគម្រោងសង់ស្នាក់ | - សហគមន៍ចិញ្ចឹមសត្វបានជោគជ័យ ។ | ៣៨០០ ដុល្លា | - ផែការអភិវឌ្ឍន៍ឃុំ និងអង្គការ | ២០០៩ | ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| - ផ្តល់មុខរបរបន្ថែម<br>- សង់ស្នាក់សហគមន៍<br>- ពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍ ។<br>- ផ្តល់ពូជសត្វសំរាប់ចិញ្ចឹម ។<br>- សង់បង្គន់អនាម័យ<br>- ផ្តល់ធុងចំរោះទឹកស្អាតឬបុកអណ្តូងស្អប់ ។<br>- ផ្តល់សម្ភារៈប្រើប្រាស់សំរាប់បំរើកាងារសហ-គមន៍នេសាទ ។ | ការសហគមន៍ ។<br>- ទិញពូជសត្វគោ និងក្របីដាក់ឱ្យសមាជិកសហគមន៍ចិញ្ចឹម ឬធ្វើជាធនាគារសត្វ<br>- ធ្វើសំណើសុំតាមរយៈអង្គការនានា រដ្ឋាភិបាល និងផ្សព្វផ្សាយឱ្យយល់ពីបញ្ហាសុខភាព និងអនាម័យ ។<br>- បំពាក់សម្ភារៈ | - សមាជិកមានចំណូលពីមុខរបរបន្ថែម ។<br>- សហគមន៍រស់នៅក្នុងបរិស្ថានស្អាត និងពុំមានជំងឺ ។<br>- សហគមន៍យល់ពីសុខភាព និងអនាម័យ ហើយប្រើបង្គន់ និងទឹកស្អាតបានគ្រប់គ្នា ។<br>-សហគមន៍មានសម្ភារៈសំរាប់បំរើការងារគ្រប់គ្រាន់ ។ | | - បដិភាគពីសមាជិកសហគមន៍ ។ | | | |

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០០៨ | | | | | | | | | | | | ២០០៩ | | | ២០១០ | | |
| | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | .... | ធ្នូ | មករា | ... | ធ្នូ |
| ១-ការប្រើប្រាស់ឧបករណ៍នេសាទ | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — |
| ២-ការកែលំអដែននេសាទ | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | | |
| ៣-រៀបចំកន្លែងអភិរក្ស | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — |
| ៤-ការគ្រប់គ្រងព្រៃលិចទឹក | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — |
| ៥-ការធ្វើវារីវប្បកម្ម | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — |
| ៦-ផែនការថវិការទ្រទ្រង់សហគមន៍ | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — |
| ៧-ផ្តល់បច្ចេកទេសដាំដុះ និងចិញ្ចឹមសត្វ | — | — | — | — | | | | | | | | | | | | | | |
| ៨-ផ្តល់មុខរបរបន្ថែម | | — | — | — | — | | | | | | | | | | | | | |
| ៩-សង់ស្នាក់ការ និងបំពាក់សម្ភារៈ | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — |
| ១០-ពង្រឹងសមត្ថភាពគណៈកម្មការ | | | | — | — | — | — | — | — | — | — | — | — | — | — | | | |
| ១១-ផ្តល់ពូជសត្វ និងដំណាំ | | | — | — | | | | | | | | | | | | | | |
| ១២-សង់បង្គន់ និងអណ្តូងស្នប់ ឬធុងចំរោះ | | | | — | — | — | — | — | — | — | — | — | — | — | — | | | |

ឆ្នោះខាង ថ្ងៃទី 17 ខែ 10 ឆ្នាំ ២០០8

ប្រធានគណៈកម្មការសហគមន៍នេសាទ

ឌាង សារ៉េន

លេខ : 0268

បានឃើញ

មេឃុំ ...........

...........ថ្ងៃទី 17 ខែ 10 ឆ្នាំ ២០០8

លេខ : 400/08

បានឃើញ និងបញ្ជូនមក

លោកនាយ រដ្ឋបាលជលផល

នាយសង្កាត់រដ្ឋបាលជលផល...........

...........ថ្ងៃទី 17 ខែ 10 ឆ្នាំ ២០០8

លេខ :...............

បានឃើញ និងបញ្ជូនមក

លោកនាយអធិការដ្ឋាន រដ្ឋបាលជលផល...........

...........ថ្ងៃទី 21 ខែ 10 ឆ្នាំ ២០០ 8

នាយខណ្ឌរដ្ឋបាលជលផល...........

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ "

...........ថ្ងៃទី 27 ខែ 11 ឆ្នាំ ២០០8

នាយអធិការដ្ឋាន រដ្ឋបាលជលផល...........

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ.............ឆ្នាំ ២០០

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល